ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN

ឆ្នាំទី ០១ លេខ ១០ ខែតុលា ឆ្នាំ ២០១៥ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION



# បទពិសោធន៍ជោគជ័យកសិករជ័យលាភី វ៉ាយ កន ក្នុងការកែច្នៃថ្នាំពុល ផ្សំពីរុក្ខជាតិ និងការកែច្នៃបន្លែ

## ប្រវត្តិសង្ខេបៈ

កសិករ **វ៉ាយ កន** មានទីលំនៅភូមិស្នាកោះ ឃុំកោះស្រឡាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

សព្វថ្ងៃគាត់មានកូន៧នាក់ ស្រី ៣នាក់ មានផ្ទៃដីស្រែ ២ ហិកតា ក្នុងនោះមានផ្ទៃសម្រាប់ដាំបន្លែ ៦៧៥ ម៉ែត្រការ៉េ។ ការប្រកបរបរចិញ្ចឹមជីវិតរបស់គាត់ពឹងផ្អែកលើការដាំដុះដំណាំស្រូវ ការដាំបន្លែ និងចិញ្ចឹមសត្វ មាន់ទា ក្របី និងជ្រូក)។



## ប្រវត្តិនៃការដាំដុះ

មុនពេលទទួលការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងការទស្សនៈកិច្ចសិក្សា ពីការធ្វើស្រែ តាម ប.រ.ស និង បន្លែធម្មជាតិ ការធ្វើស្រែរបស់គាត់ គឺធ្វើតាមទម្លាប់ ពីបុរាណ។

ចំពោះបន្លែដាំតាមទម្លាប់គឺប្រើជីគីមីនិងថ្នាំពុលគីមីសម្លាប់សត្វល្អិត។ ចំពោះការស្រោចស្រោពវិញគឺរែកទឹកពីទន្លេ ក្នុង១ថ្ងៃ ស្រោចពីរដង១០០ ទៅ ១៥០ ជើង។ រាល់ពេលដែលគាត់ បាញ់ថ្នាំកម្ចាត់សត្វល្អិត គាត់តែងតែឈឺក្បាល ចង់ក្អួតចង្អោរ និងក្រុមគ្រួសាររបស់គាត់តែងតែឈឺមិនដាច់សោះ។ ចំពោះលទ្ធផលវិញចំណេញតិចតួចក្រោយពីផាត់ជីគីមី និង ថ្នាំពុលសម្លាប់សត្វល្អិត និងពូជចេញ។

នៅឆ្នាំ២០០៤ គម្រោងអង្គការ អុស្វាមអូស្ត្រាលី សហការជាមួយមន្ទីរកសិកម្មខេត្ត គាត់បានចូលរួមបណ្តុះបណ្តាលស្តីពី ៖

- ប.រ.ស
- បច្ចេកទេសដាំដុះបន្លែតាមគោលការណ៍ធម្មជាតិ

និង ទៅទស្សនៈកិច្ចសិក្សា អំពីដំណាំបន្លែ ធម្មជាតិ និងការអនុវត្ត ប.វ.ស នៅខេត្តតាកែវ

- ជាហេតុធ្វើឱ្យគាត់ យល់ច្រើន ពីការប្រើជីធម្មជាតិ និង ថ្នាំពុលធម្មជាតិ ជាពិសេស ផលប៉ះពាល់ថ្នាំពុលគីមី និង ជីគីមី ចំពោះ សុខភាព។

ក្រោយពីបានទៅទស្សនៈកិច្ចសិក្សា និង ចូលរួមវគ្គបណ្តុះបណ្តាល និង ការណែនាំបច្ចេកទេសពីមន្ត្រីកសិកម្មខេត្តមក គាត់បានយកបច្ចេកទេសទាំងនេះទៅអនុវត្តការដាំដុះរបស់គាត់។

- ចំពោះស្រូវ គឺអនុវត្តតាម ប.វ.ស
- ចំពោះបន្លែដាំតាមគោលការណ៍ធម្មជាតិ ដោយប្រើជីកំប៉ុស្ត និង ថ្នាំពុលផ្សំពីរុក្ខជាតិ

## ចំពោះការធ្វើជីកំប៉ុស្តិ៍ ៖

- ការធ្វើជីកំប៉ុស្តគោក ៖ គឺយើងធ្វើរោង ហើយប្រមូលលាមកសត្វ ដាក់ចូល និង ចិញ្ច្រាំទន្រ្ទានខែត្រ ស្លឹកឈើ និងកាកសំណល់ផ្ទះបាយ ហើយស្រោចទឹកពេលណាពិនិត្យឃើញជីស្ងួត និងច្របល់១០-១៥ថ្ងៃម្តង ទុករហូត កាច់ផុយដូចដី ទើបអាចប្រើបាន គឺ ១រងទំហំ១ ម៉ែត្រ គុណ១៥ម៉ែត្រ ប្រើ ៥០គ.ក្រ
- ជីកំប៉ុស្តទឹក ៖ យកទន្រ្ទានខែត្រ ១០ គីឡូក្រាម លាមកក្របីស្រស់ ១០គីឡូក្រាម ទឹកនោម ២០ លីត្រ រួចយកមកត្រាំក្នុងទឹក ៥០ លីត្រ ក្នុងពាងជាមួយគ្នា ផ្អាប់ទុករយៈពេល១៥ថ្ងៃ ដោយកូរវារៀងរាល់ថ្ងៃ ទើបយកមកប្រើនៅលើដំណាំបន្លែ។ ក្នុង ១លីត្រ ជី លាយទឹកចំនួន ១០ លីត្រ ស្រោច ៣ថ្ងៃម្តង។



## វិធីកែច្នៃធ្វើថ្នាំពុលធម្មជាតិ

### ធាតុផ្សំ

- មើមប្រង់ ១០គ.ក្រ
- ស្លឹកគ្រៃ ២ គ.ក្រ
- ឈើភ្លើង ៥ គ.ក្រ
- គ្រាប់ស្លែងធំ ៥ គ.ក្រ
- មើមក្រវាញជ្រូក ៥ គ.ក្រ
- មើមរំដេង ៥ គ.ក្រ
- ផ្លែស្លាក់ ៥ គ.ក្រ
- វល្លិ៍ពេជ្រ ១០ គ.ក្រ
- មើមក្តួច ១០ គ.ក្រ
- មើមក្បៀង ៥ គ.ក្រ
- ម្ទេសទុំ ២ គ.ក្រ
- ថ្នាំខ្លាំង ២ គ.ក្រ



### តាមបទពិសោធន៍របស់កសិករ

ចំពោះដំណាំយកស្លឹក និងដំណាំស្រូវ ការផ្សំថ្នាំពុលយើងប្រើធាតុផ្សំតាមតែអាចរកបាន។

ប៉ុន្តែចំពោះដំណាំប្រភេទ វារ មានទង យើងមិនអាចផ្សំថ្នាំពុលមានជាតិហិល និងក្តៅបានទេ ព្រោះដំណាំនេះពេលណាប្រើជាតិហិល និងក្តៅធ្វើឱ្យស្រពោនស្លោករួញ។

## របៀបធ្វើ

- យកធាតុផ្សំទាំងអស់ចិញ្ច្រាំ ហើយបុកឱ្យម៉ត់ ទើបយកដាក់ក្នុងពាង។
- យកទឹកស្អាតចាក់ចូលក្នុងពាង ចំនួន ២០លីត្រ បិទគម្របឱ្យជិត និងគ្រប់គ្រងឱ្យល្អ

- ក្នុង១ថ្ងៃ បើកគ្របកូរ១ ដង ដើម្បីឱ្យវត្ថុធាតុទាំងអស់ឆាប់កាច់។ ធ្វើរបៀបនេះរហូត ១៥-២០ថ្ងៃ ទើបអាចប្រើបាន។



## របៀបប្រើ

បន្ទាប់ពីត្រាំរយៈពេល ១៥-២០ថ្ងៃមក យកថ្នាំត្រងនឹងស្បៃ ដើម្បីយកកំទិចកំទីចេញ។ ពេលប្រើ ថ្នាំ១លីត្រលាយទឹក៨-១០លីត្រ បាញ់នៅពេលល្ងាចត្រជាក់ ព្រោះថ្នាំ អាចជាប់នៅលើដំណាំ បានយូ ហើយសត្វល្អិតភាគច្រើនចេញស៊ីដំណាំ នៅពេលល្ងាច ឬ ពេលយប់ត្រជាក់ បាញ់ ពីគល់បាចឡើងលើ ព្រោះដង្កូវភាគច្រើននៅក្នុងដី នៅក្រោមស្លឹក។ ការបាញ់ត្រូវធ្វើ ៤-៥ ថ្ងៃម្តង។



- ចំពោះការស្រោចស្រពវិញ គាត់បានជីក ស្រះនៅក្បែរចម្ការបន្លែសម្រាប់បូមទឹកពីទន្លេស្តុកទឹកទុកស្រោច និងអាចចិញ្ចឹមត្រីផងដែរ។
- ការស្រោចស្រពបន្លែនៅតូច គឺ ស្រោចដោយធុងរ៉ែកទឹកស្រោចផ្ទាល់ដៃ។
- ពេលបន្លែដុះលូតលាស់ធំបន្តិច អាចស្រោចដោយកែច្នៃ ប្រើម៉ាស៊ីនមានតទុយយោ ដាក់ផ្ការឈូកបូមទឹកពីស្រះស្រោចដូចទឹកភ្លៀង។



ចំពោះផលិតផលបន្លែ ពេលណានៅទីផ្សារមានតម្លៃថោកពេក លក់មិនអស់ យើងអាច យកមកកែច្នៃទុកលក់បានថែមទៀត នៅក្នុងភូមិ និងទីផ្សារ ដូចជា ត្រសក់កែច្នៃជា ត្រសក់ជ្រក់ ត្រសក់ចារ ស្ពៃកែច្នៃជាស្ពៃជ្រក់ ឆៃថាវកែច្នៃជាឆៃពៅ

## បទពិសោធន៍ធ្វើស្ពៃជ្រក់

គ្រឿងផ្សំ

- ស្ពៃ ១០ គីឡូក្រាម
- អំបិល ១-២ គីឡូក្រាម
- ស្ករត្នោត ០.២-០.៣ គីឡូក្រាម
- អង្ករ ២-៣ កំប៉ុង
- ប៊ីចេង បន្តិចបន្តួច

### របៀបធ្វើ

- យកស្ពៃលាងទឹកឱ្យស្អាត ហាលថ្ងៃ ឱ្យស្រពាប់បន្តិច
- ដាំទឹកឱ្យពុះ រួចយកស្ពៃស្រុះក្នុងទឹកក្តៅ ត្រឡប់ចុះឡើងឱ្យស្រពាប់ល្មម
- យកស្ពៃដែលស្រុះរួចដាក់ដម្រាបក្នុងពាង ខាប់ ឬ ធុង( ស្ពៃត្រូ)
- ដាំទឹកអំបិលឱ្យពុះ ទុកឱ្យត្រជាក់ រួចចាក់ចូលក្នុងពាង ស្ពៃ ករណីចង់ទុក ឱ្យបានយូត្រូវដាក់អំបិលឱ្យប្រៃបន្តិច
- ពិនិត្យមើលលើទីផ្សារស្ពៃជ្រក់ ។ យកអង្ករមកត្រាំ

ទឹក១យប់ ហើយកិនជាម្សៅ រួចចាក់ចូលក្នុងពាងស្ពៃ ។

- យកស្ករត្នោតរំងាស់ឱ្យពុះ ទុកឱ្យត្រជាក់ចាក់ចូលក្នុងពាងស្ពៃគ្របទុក ១យប់ ឬពីយប់មើលស្ពៃជូរល្មមហើយ ទើបអាចលក់បាន ។





## បទពិសោធន៍ធ្វើត្រសក់ជ្រក់

### គ្រឿងផ្សំ

- ត្រសក់ ១០ គីឡូក្រាម
- អំបិល ១-២ គីឡូក្រាម
- ស្ករត្នោត ០.២ គីឡូក្រាម
- ម្សៅស៊ុប (ប៊ីចេង) បន្តិចបន្តួច



### របៀបធ្វើ

- យកត្រសក់ លាងទឹកឱ្យស្អាត រួចចិត បណ្តោយត្រសក់ ហាលថ្ងៃឱ្យស្រពាប់ តម្រាបចូលក្នុងឆ្នាំង
- ដាំទឹកអំបិលឱ្យពុះ ទុកឱ្យត្រជាក់ រួចចាក់ចូលក្នុងឆ្នាំងត្រសក់ ករណីចង់ទុកបានយូរ ត្រូវដាក់អំបិលឱ្យប្រៃបន្តិច គ្របទុក ១-២ យប់ រួចរំងាស់ស្ករត្នោត ចាក់ចូលក្នុងឆ្នាំងត្រសក់ទុក ១ យប់ អាចយកមកលក់បាន៕

---


### សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកៈ

- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
អាសយដ្ឋាន ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ
  - ទូរស័ព្ទលេខ : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥
  - ទូរសារលេខ : (៨៥៥)២៣ ២១០ ៩៤៨
  - Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម -Department of Agricultural Extension
  - គេហទំព័រ : http://www.maff.gov.kh
- លោក **វ៉ាយ ភន** កសិករជ័យលាភី ក្នុងការកែច្នៃថ្នាំពុល ផ្សំពីរុក្ខជាតិ និងការកែច្នៃបន្លែតាមអាសយដ្ឋាន មានទីលំនៅភូមិស្នាកោះ ឃុំកោះស្រឡាយ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង៕